# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៦០៩

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តទៅ

## នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ.នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥

ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា ៣ មាត្រា ៤ មាត្រា៦ មាត្រា ៨ មាត្រា ៩ និងមាត្រា១៣ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៨/៣១១ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា២ថ្មី និងមាត្រា១៣ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី១

## ស្តីពីការកំណត់សមាសភាព តួនាទី និងរចនាសម្ព័ន្ធរបស់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**មាត្រា១ .-**

ត្រូវបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អក្សរកាត់ អ.ជ.ប.គ.ញ.) ដែលមានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី ០១ រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- រដ្ឋមន្ត្រីក្រសួងពត៌មាន សមាជិក
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី សមាជិក
- រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក
- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សមាជិក
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក
- រដ្ឋមន្ត្រីក្រសួងសាធារណៈការ និង ដឹកជញ្ជូន សមាជិក
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- អគ្គលេខាធិការ នៃ អ.ជ.ប.គ.ញ. សមាជិក និង ជាលេខាធិការ

ក្នុងករណីចាំបាច់ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អាចស្នើសុំតែងតាំងឥស្សរៈជន ០១ រូប ជាអនុប្រធាន មានឋានៈស្មើរដ្ឋមន្ត្រី ។

**មាត្រា២ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តបទប្បញ្ញត្តិអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និង សារធាតុដែលធ្វើឱ្យប៉ះពាល់សរសៃប្រសាទ ឆ្នាំ១៩៨៨ និង បទដ្ឋានគតិយុត្តិអន្តរជាតិនានាស្តីពីគ្រឿងញៀន

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីទប់ស្កាត់ ការដាំដុះ ការផលិត ការចរាចរ ការជួញដូរគ្រឿងញៀន និង សារធាតុគីមីផ្សំគ្រឿងញៀន
- អប់រំ ផ្សព្វផ្សាយ លើកកំពស់ការយល់ដឹងអំពីបញ្ហាគ្រឿងញៀនដល់សាធារណៈជន ដើម្បីកាត់បន្ថយ និង ឈានទៅលុបបំបាត់តំរូវការគ្រឿងញៀន ការផ្គត់ផ្គង់គ្រឿងញៀន និងការប្រើបំពានគ្រឿងញៀន
- គ្រប់គ្រង និងបង្កើតមជ្ឈមណ្ឌលអប់រំ ព្យាបាល និងស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកជាសះស្បើយពីគ្រឿងញៀនចូលក្នុងសហគមន៍ និងគ្រួសារវិញ
- ទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានាដើម្បីស្វែងរកមូលនិធិសម្រាប់សកម្មភាពបង្ការទប់ស្កាត់បទល្មើសគ្រឿងញៀន
- ដឹកនាំ សម្របសម្រួល និង អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំតាក់តែងអត្ថបទច្បាប់ និងបទដ្ឋានគតិយុត្ត ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- លើកទឹកចិត្តដល់អ្នកផ្តួចផ្តើមគំនិតក្នុងការប្រយុទ្ធប្រឆាំងនឹងជំនួញគ្រឿងញៀន សារធាតុសំរាប់ផ្សំគ្រឿងញៀន និងការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់
- អាជ្ញាធរជាតិ ត្រូវធានាអនុវត្តកាតព្វកិច្ចដែលមានចែងក្នុង អនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ព្រមទាំងដាក់ឱ្យអនុវត្តនូវយន្តការជាតិនិងអន្តរជាតិ ដើម្បីធានានិរន្តរភាពសំរាប់ការត្រួតពិនិត្យគ្រឿងញៀន
- អនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**មាត្រា៣ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ និងមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជាខ្សែបណ្តោយ ។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំបង្កើតគណៈកម្មាធិការសំរាប់បំពេញមុខងារតាមជំនាញ ។ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤ ..**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានត្រាប្រើប្រាស់ជាផ្លូវការ ។

**មាត្រា៥ ..**

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំមន្ត្រីពីក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំមន្ត្រីមានក្របខ័ណ្ឌពីស្ថាប័ននានាមកបំរើការងារនៅអគ្គលេខាធិការដ្ឋាន នៃអ.ជ.ប.គ.ញ បើយល់ឃើញថាចាំបាច់ ។

**មាត្រា៦ ..**

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំតែងតាំង ឬ តំលើងឋានន្តរស័ក្តិ ឬ ដាក់ពិន័យមន្ត្រីរាជការក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ បន្ទាប់ពីមានការយល់ព្រមពីប្រធានស្ថាប័នដែលគ្រប់គ្រងមន្ត្រីនោះ ។

**មាត្រា៧ ..**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ ។

គ្រប់ពេលប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រសិនបើសមាជិកណាម្នាក់មានធុរៈមិនអាចចូលរួមប្រជុំបាន សមាជិកនោះត្រូវចាត់តាំងតំណាងមួយរូបដែលមានសិទ្ធិសំរេចមកចូលរួមជំនួស ។

ក្នុងករណីចាំបាច់ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អាចអញ្ជើញប្រធានស្ថាប័ន និងបុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងរបៀបវារៈចូលរួមប្រជុំ ។

## ជំពូកទី២

## អំពីអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**មាត្រា៨ ..**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃក្រសួងមហាផ្ទៃ ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ ត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និង មានអគ្គលេខាធិការរងជាជំនួយ ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

**មាត្រា៩ .-**

អគ្គលេខាធិការ និង អគ្គលេខាធិការរង នៃអ.ជ.ប.គ.ញ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និង អនុក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី និង តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៣
## អំពីធនធាន និងថវិកា

**មាត្រា១០ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានថវិកា ដើម្បីអនុវត្តការងាររបស់ខ្លួន ។ ធនធាននិងថវិកានេះបានមកពី ÷

- ថវិកា ដែលជាកញ្ចប់ដោយឡែក ក្នុងកញ្ចប់ថវិការបស់ក្រសួងមហាផ្ទៃ
- ប្រាក់ជំនួយ អំណោយ ឬវិភាគទានដែលផ្តល់ជូនអាជ្ញាធរជាតិ ដោយរដ្ឋាភិបាលបរទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និង សប្បុរសជន សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ទ្រព្យ និង វត្ថុដទៃទៀត ដែលបានមកដោយការអនុវត្តន៍សេចក្តីសម្រេចរឹបអូសរបស់តុលាការពីជនួញគ្រឿងញៀនខុសច្បាប់ដែលបានបញ្ចូលទៅក្នុងបេឡាមូលនិធិនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**មាត្រា១១ .-**

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនត្រូវបានទទួលការតែងតាំងអោយអនុវត្តសិទ្ធិអាណាប័កជំនួស "អាណាប័កផ្ទេរសិទ្ធិ" តាមការសម្រេចចិត្តរបស់អាណាប័កដើមខ្សែ ។

**មាត្រា១២ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុម័តការប្រើប្រាស់មូលនិធិរបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ និងត្រួតពិនិត្យការប្រើប្រាស់ថវិការបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ព្រមទាំងមានសិទ្ធិចាត់ចែងថវិកា និងទ្រព្យសម្បត្តិដែលបានបញ្ចូលទៅក្នុងបេឡាមូលនិធិដូចមានចែងក្នុងមាត្រា ១០ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១៣ ._**

ត្រូវបានទុកជានិរាករណ៍ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣១១ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ។

**មាត្រា១៤ ._**

ការអនុវត្តន៍ភ្លាមនៃព្រះរាជក្រឹត្យនេះ ពុំមានអានុភាពលើសុពលភាពនៃបទដ្ឋានគតិយុត្តិទាំងឡាយដែលបាននិងកំពុងបំពេញដោយអនុលោមទៅតាមព្រះរាជក្រឹត្យដែលត្រូវបាននិរាករណ៍តាមមាត្រា ១៣ នៃព្រះរាជក្រឹត្យនេះរហូតដល់មានបទដ្ឋានគតិយុត្តិថ្មីមកជំនួស ។

**មាត្រា១៥ ._**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**មាត្រា១៦ ._**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០៩*

*៣៧ល.០៩០៥.៦១៤*

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៥៥៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន